BMI0198

**សម្ភាសន៍ជាមួយឈ្មោះ ចាប សាន ភេទប្រុស អាយុ៤៧ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ទាហានក្នុងកងពល៥១៩**

**ស្រុកកំណើតនៅភូមិស្តុកឃ្លោក ឃុំព្រះម្លូ ស្រុកបាកាន ខេត្តពោធិ៍សាត់**

**រស់នៅភូមិជន្លៀសដៃ ឃុំគោកកថិន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ ឡុង ដានី**

០០:៤៣:១០

**១៩ទំព័រ**

សាន : គ្រាន់តែដឹងថាគេបញ្ជាខ្ញុំហ្នឹងឲ្យដឹកប្រពន្ធគាត់ប្រជុំចុះឡើងៗប៉ុណ្ណោះ ។

ដានី : ពូឈ្មោះអីដែរ ខ្ញុំចង់ស្គាល់ឈ្មោះពូ?

សាន : ខ្ញុំឈ្មោះ ចាប សាន ។

ដានី : ពូអាយុប៉ុន្មានហើយ?

សាន : អាយុ៤៧ហើយ ។

ដានី : ពូស្រុកកំណើតនៅណាដែរ?

សាន : នៅខាងពោធិ៍សាត់ ។

ដានី : ភូមិអីដែរនៅខាងពោធិ៍សាត់?

សាន : ភូមិស្តុកឃ្លោក ឃុំព្រះម្លូរ ។

ដានី : ភូមិស្តុកឃ្លោក ស្រុកព្រះម្លូរ?

សាន : ស្រុកបាកាន ។

ដានី : ខេត្តពោធិ៍សាត់ ។ សព្វថ្ងៃភូមិអីគេភូមិហ្នឹង?

សាន : ភូមិជន្លៀសដៃ ។

ដានី : ពូរស់នៅភូមិជន្លៀសដៃ ឃុំអី?

សាន : ឃុំគោកកថិន ។

ដានី : ស្រុក?

សាន : ស្រុកថ្មពួក ។

ដានី : ខេត្តបន្ទាយមានជ័យ ។ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

សាន ៖ ឈ្មោះកែវ សារ៉ែប ។

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

សាន ៖ គាត់អាយុ៣៨ ។

ដានី ៖ គាត់អ្នកស្រុកភូមិណាដែរ?

សាន ៖ ស្រុកកំណើតនៅហ្នឹងហ្នង ។

ដានី ៖ សព្វថ្ងៃពូមានកូនចៅប៉ុន្មាននាក់ហើយ?

សាន ៖ មាន៣នាក់ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន ។

សាន ៖ ប្រុស២ ស្រី១ ។

ដានី ៖ សព្វថ្ងៃពូធ្វើការងារអីដែរ?

សាន ៖ នៅជួរខេមរភូមិន្ទភ្នំពេញ ។

ដានី ៖ កងទ័ពនៅណា?

សាន ៖ នៅស៊ុបយើងនេះឯង ។

ដានី ៖ ស៊ុបនៅបន្ទាយមានជ័យហ្នឹង?

សាន ៖ បាទ!

ដានី ៖ តួនាទីអីដែរពូ?

សាន ៖ តួនាទីតិចតួចហ្នឹង ជំនាញខាងហិរញ្ញវត្ថុ ។

ដានី ៖ ខាងហិរញ្ញវត្ថុ?

សាន ៖ បាទ!

ដានី ៖ តែពូអត់ដែលទៅបន្ទាយទេ?

សាន ៖ យូៗទៅម្តង ព្រោះយើងការងារអញ្ចឹង ដល់ខែបានយើងបានទៅ ។

ដានី ៖ នៅផ្ទះនៅមានមុខរបរផ្សេងទៀតទេ?

សាន ៖ ធ្វើស្រែ ។

ដានី ៖ ពូចេញពីស្រុកកំណើតតាំងពីអង្កាល់?

សាន ៖ បើនិយាយរួមតាំងពីតូច ។

ដានី ៖ តាំងពីតូចហ្នឹង តាំងពីអាយុប៉ុន្មានទៅ?

សាន ៖ បើនិយាយរួមទៅតាំងពីអាយុ៤-៥ឆ្នាំ ប៉ុន្តែយើងមកនៅមុនគេជម្លៀសនៅអូរជ្រៅប៉ោយ ប៉ែតយើងនេះ ។

ដានី ៖ ចេញមកជាមួយឪពុកម្ដាយមែនទេ?

សាន ៖ បាទ!

ដានី ៖ ឪពុកពូគាត់ឈ្មោះអីដែរ?

សាន ៖ ឈ្មោះ ចាប ផង់ ។

ដានី ៖ សព្វថ្ងៃគាត់នៅទេ?

សាន ៖ ស្លាប់អស់ហើយ ។

ដានី ៖ ស្លាប់ពីអង្កាល់?

សាន ៖ ទើបតែស្លាប់៣-៤ឆ្នាំមុននេះ ។

ដានី ៖ ចុះម្ដាយ?

សាន ៖ ស្លាប់ឆ្នាំ៧៩ ។

ដានី ៖ គាត់ស្លាប់ដោយសារអីឆ្នាំ៧៩ហ្នឹង?

សាន ៖ ឈឺ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

សាន ៖ ឈ្មោះ នាក់ វ៉ា ។

ដានី ៖ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

សាន ៖ ៥នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សាន ៖ ស្រី៣ ប្រុស២ ។

ដានី ៖ ពូកូនទីប៉ុន្មាន?

សាន ៖ ខ្ញុំកូនពៅគេ ។

ដានី ៖ ពៅគេបង្អស់ហ្នង?

សាន ៖ បាទ!

ដានី ៖ បានរៀនសូត្រទេកាលពីក្មេងៗ?

សាន ៖ រៀនបានតិចតួច រៀនយើង បើនិយាយទៅឆ្នាំ៨០ដាងរៀននៅខាងក្នុងហ្នឹងឯង ។

ដានី ៖ អញ្ចឹងពូចាំពេលចេញពីផ្ទះហ្នឹងឆ្នាំណាទេ?

សាន ៖ ១៩៨៤ ។

ដានី ៖ ចេញឆ្នាំ៨៤ មូលហេតុអីបានជាចេញឆ្នាំ៨៤?

សាន ៖ ចេញមកហ្នឹង បើនិយាយរួមទៅចេញមករៀនសូត្រ គេចេញទៅរៀនដូចថានៅជំរុំគេមានរៀនមានអីអញ្ចឹង យើងមករៀនណា៎ ដល់ពេលចេញមកមេកងពលហ្នឹងឃើញ ដល់ឃើញទៅក៏មិនឲ្យរៀនឲ្យធ្វើទ័ពហ្នឹងរហូតតាំងពីតូចមក ។

ដានី ៖ ចេញកាលឆ្នាំ៨៤ កាលហ្នឹងពូអាយុប៉ុន្មាន?

សាន ៖ មិនដឹងអាយុប៉ុន្មានទេកាលហ្នឹង កាល៨៤ដក៨៧ទៅឃើញហើយ ។

ដានី ៖ កាលហ្នឹងចេញមកម្នាក់ឯង ឬក៏ចេញមក?

សាន ៖ ចេញមកម្នាក់ឯង ឪពុកជូនមករកបងម្នាក់ដែលធ្វើខ្មែរក្រហម បងម្នាក់នៅខ្មែរក្រហមតាំងពី៧៥ តាំងពីចល័តមក ។ មករកបង ដល់ពេលមកឃើញគេឲ្យនៅធ្វើនៅហ្នឹងទៅ ។

ដានី ៖ ពេលរកឃើញនៅក្នុងកងពលណា?

សាន ៖ នៅកងពល៥១៩ ។

ដានី ៖ ចុះបងពូឈ្មោះអីដែលធ្វើការនៅហ្នឹង?

សាន ៖ ឈ្មោះ ចាប សៅ ។

ដានី ៖ ចុះកាលហ្នឹងម៉េចបានដឹងដំណឹង?

សាន ៖ កាលហ្នឹងគាត់នៅព្រៃមាន់យើងបីងត្រកួន គាត់ផ្ញើរសំបុត្រទៅឪពុកខ្ញុំ ដល់ពេលរួចឪពុកខ្ញុំមក យកខ្ញុំមកតាម ហើយខ្ញុំមានគំនិតមួយចង់រៀន ដល់ពេលមកដល់វាមិនដូចជំរុំសាយធូជំរុំសាយប៊ីណា អត់ផង ព្រោះតំបន់ខ្មែរក្រហមយើងអត់មានសាលារៀន គេឲ្យយើងធ្វើទ័ពហ្នឹងហ្នុង ។

ដានី ៖ ចុះឪពុកពូគាត់នៅជាមួយដែរ ឬក៏គាត់ទៅវិញ?

សាន ៖ ឪពុកខ្ញុំនៅខាងក្នុង គាត់ត្រលប់ទៅវិញ ។

ដានី ៖ ពេលហ្នឹងពូមកនៅជាមួយបងទៅ?

សាន ៖ នៅជាមួយគាត់ហ្នឹង គាត់នៅខាងខណៈទាក់ទងថៃ-ខ្មែរ បងខ្ញុំហ្នឹងណា៎ ដល់ពេលរួចមេកងពលហ្នឹងគាត់ឲ្យនៅជាមួយទៅ ។

ដានី ៖ របស់កងពល៥១៩ហ្នឹង?

សាន ៖ បាទ! ៥១៩ ។

ដានី ៖ អញ្ចឹងក្រោយមក ដល់ពេលឆ្នាំ៨៤ហ្នឹង ពូមកនៅហ្នឹង នៅជាមួយប្រធានគណៈកងពល?

សាន ៈ នៅជាមួយកងពល ។

ដានី ៈ គណៈកងពលឈ្មោះអីគេ?

សាន ៈ ឈ្មោះ ឡុង ថែម ។

ដានី ៈ គាត់ប្រធានកងពលហ្នុង?

សាន ៈ និយាយរួមទៅកាលហ្នឹងគាត់ ដូចដែលតាយន នោះប្រធានកងពលគាត់របៀបមកជារង ក្រោយមកគេបំបែកពីរកងពលទៀត ។

ដានី ៈ ឈ្មោះ តាយន ហ្នឹងប្រធានកាលហ្នឹង?

សាន ៈ ហ្នឹងហើយតាយន ហ្នឹងប្រធាន ដល់ក្រោយពីគេដកតាយនហ្នឹងមក ឌុល សារឿន យើង នេះឡើងជាប្រធាន ហើយបានគេបំបែកពីរកងពល ទៅប្រចាំនៅទន្លេសាបមួយកងពល ។

ដានី ៈ តាយនហ្នឹង អ្នកនៅណា?

សាន ៈ អត់ដឹងប្រវត្តិផង ព្រោះកាលដែលខ្ញុំចូលមកដល់ហ្នឹងគេដកគាត់ទៅហើយ ។

ដានី ៈ គេហៅមានរហ័សនាមអីផ្សេងទៀតទេ ០៦មែនទេ?

សាន ៈ អត់ដឹងផង មិនដឹង០ប៉ុន្មានខ្ញុំអត់ដឹងផង បើនិយាយរួមទៅគ្រាន់តែមកដល់ហ្នឹងឡុង ថែម ហ្នឹងចូលគេដកគាត់ហ្នុង ។

ដានី ៈ តាយន ហើយឡុង ថែម?

សាន ៈ បាទ! ហើយបានឌុល សារឿន ។

ដានី ៈ ឌុល សារឿន មកហ្នឹងធំជាងឡុង ថែម ឬក៏?

សាន ៈ ធំជាង ។

ដានី ៈ គាត់ប្រធានកងពល?

សាន ៈ ព្រោះគាត់នៅនេះចាស់ ។

ដានី ៈ ក្នុងកងពលហ្នឹងចាំមើលមាន ឌុល សារឿន, ឡុង ថែម, ហើយមានពីណាទៀត?

សាន ៈ មាន កងពលហ្នឹងមាន ក្នុងនោះមានច្រើនណាស់ មានព្រំ ស៊ូ ដល់ពេលក្រោយមកមាន ប៉ែន វយ មានអីទាំងអស់ហ្នឹងឯង ។

ដានី ៈ ប៉ែន វយ ក្រោយទេ?

សាន ៈ បាទ! គាត់ឡើងក្រោយ គេបំបែកឌុល សារឿន, ប៉ែន វយ អាហ្នឹងគេបំបែក៥១៩ មួយ ហើយបំបែក៥១៨មួយ ។

ដានី ៈ ៥១៩ហើយនឹង៥១៨?

សាន ៖ បាទ! ហើយខ្ញុំនៅ៥១៨ ក្រោយមកដែលគេបំបែក ។

ដានី ៖ ៥១៨ហ្នឹងពីណាគេខ្វះនៅហ្នឹង?

សាន ៖ ឡុង ថែមប្រធាន ព្រំ ស៊ូ, ម៉ៃ ម៉ៅ នៅកងពលយើងសព្វថ្ងៃនេះ មាន៣នាក់ហ្នឹងឯង ។

ដានី ៖ ៥១៩?

សាន ៖ ៥១៩មានឌុល សារឿន, ប៉ែន វយ តារឿនខ្វាក់ ។

ដានី ៖ ប៉ែន វយ?

សាន ៖ ហើយ តារឿន, ចៅ សុខ ។

ដានី ៖ តារឿន ហ្នឹងខ្វាក់?

សាន ៖ បាទ!

ដានី ៖ គាត់ខ្វាក់មួយចំហៀង?

សាន ៖ គាត់ខ្វាក់មួយខាង ។

ដានី ៖ ហើយនឹងចៅ សុខ ។ កងពល៥១៨ហើយ៥១៩ហ្នឹងនៅជាមួយគ្នា ឬក៏ទិសខុសគ្នា?

សាន ៖ ទិស៥១៨នៅទន្លេសាប នៅក្រោមយើងអន្លុង្គបុរីនេះ បែកកងមាត់ដបនេះ ហើយ៥១៩ គេនៅមួយជួរនេះទាំងអស់ ប៉ុន្តែការឆ្លងកាត់រស់នៅជុំគ្នា ។

ដានី ៖ ស៊ីសុផុនខាងជើង?

សាន ៖ ស៊ីសុផុនខាងជើងជារួម ។

ដានី ៖ តែនៅជាមួយគ្នាទេ?

សាន ៖ នៅជាមួយគ្នា ការដឹកនាំការអីហ្នឹងវាតែមួយ ។

ដានី ៖ ក្រោមការដឹកនាំរបស់ពីណាទៀត?

សាន ៖ របស់ សូ ហុង ។

ដានី ៖ សូ ហុង គាត់មកពីណាដែរ?

សាន ៖ សូ ហុង មកពីខាង ចេញពីអៀង សារី មក និយាយរួមគាត់គណៈសមរភូមិ ។

ដានី ៖ អៀង សារី កាលហ្នឹងគាត់នៅណា គាត់អាសាររមកទេ?

សាន ៖ គាត់អាសាររមក គាត់នៅម៉ាឡៃ ។

ដានី ៖ គាត់អាសាររមកជួបពូដែរ?

សាន ៖ ទីស្នាក់ការគាត់នៅភ្នំឆ័ត្រមួយ ។

ដានី ៖ នៅភ្នំឆ័ត្រ?

សាន : បាទ!

ដានី : អញ្ចឹងពូនៅតាំងពីឆ្នាំ៨៤មក នៅជាមួយ?

សាន : នៅជាមួយឡុង ថែម រហូត ។

ដានី : អញ្ចឹងនៅរហូតហ្នឹង គាត់នៅកន្លែង នៅម៉ាជួរខាងទន្លេសាប?

សាន : បែកកងមាត់ដប ។

ដានី : កាលហ្នឹងពូវៃម៉ាជួរខាងហ្នឹងទាំងអស់?

សាន : វៃខាងនោះទាំងអស់ ម៉ាជួរគុយម៉េង ម៉ាជួរខ្លាខាំភ្លេ ម៉ាខាងហ្នឹងទាំងអស់ វៃមកដល់ស្ពាន ស្នេហ៍ស្ពានអី ផ្លូវយើងនេះ ទៅត្បូងហ្នឹងព្រំប្រទល់យើងខាង...ខាងកើតថ្មគោល ទៅកើត ទៅខាងអាម៉ាល់បត់ត្រង់យើងនោះ ខាងក្រឡាញ់ មកជើងនេះខាងភ្នំលាប ។

ដានី : ចុះខាងម៉ាឡៃខាងកងពលគេផ្សេង?

សាន : ខាងម៉ាឡៃ៤៥០ផ្សេង ។

ដានី : តាភាព?

សាន : បាទ! តាភាព ។

ដានី : ចុះឆ្នាំណាទៅបានពូបានជួប តាពិន?

សាន : ឆ្នាំ៩០-៩១ដែលគេវៃបែកស្វាយចេកហើយ ។

ដានី : ជួបហ្នឹងគាត់យ៉ាងម៉េច ពូអាចជួយរៀបរាប់ប្រាប់បានទេ?

សាន : បើនិយាយរួមទៅ ជួបហ្នឹងគឺថាគាត់ហ្នឹងមិនដឹង បើនិយាយឲ្យច្បាស់ទៅថាគាត់ហ្នឹងមិនដឹង មកពីខាងណាទេ ប៉ុន្តែគេផ្ញើរតាមរយៈឡុកងទ័ពនៅមុំនេះមើលគាត់ អត់ដឹងថាគាត់ហ្នឹងផ្ញើ តួនាទីខាងអីទេ អត់ដឹងទេ មានតែគេបញ្ជាមកថាឲ្យដឹកខាងនេះដឹកខាងនោះចេះតែដឹកទៅ ណា៎ យើងអត់ដឹងផ្ទៃក្នុងរបស់គេ ហើយគាត់ហ្នឹងក៏មិនបានអួតមិនបានអាងថាគាត់ហ្នឹងផ្ញើ នេះផ្ញើនោះអត់ គឺអត់ហ្នង សាម័ញ្ញធម្មតា ។

ដានី : ចុះកាលហ្នឹងគេផ្ញើរហ្នឹងយ៉ាងម៉េចដែរ?

សាន : គេផ្ញើរហ្នឹងក្នុងនាមប្រពន្ធគាត់ហ្នឹងជាប្រធានសមាគមន៍នារី ក្នុងហ្នឹងមាន២នាក់ មានយាយ មឿន មួយទៀត ។

ដានី : សមាគមន៍នារីនៅណា?

សាន : សមាគមន៍នារីនៅម៉ាឃុំផ្កាំហ្នឹង មានតែឃុំផ្កាំមួយទេ គោកកបិនអត់ទាន់មានទេ ។

ដានី : ឃុំផ្កាំ ជាមួយឈ្មោះអីប្រពន្ធគាត់?

សាន ៖ ឈ្មោះ យាយរ៉ុម តែមិនដឹងត្រកូលគាត់ឈ្មោះអីទេ ដឹងតែយាយរ៉ុម ។

ដានី ៖ យាយរ៉ុម នឹងយាយមឿន?

សាន ៖ បាទ! យាយមឿន ។

ដានី ៖ យាយមឿន ហ្នឹងប្រពន្ធអ្នកណាគេដែរ?

សាន ៖ ប្រពន្ធតាដាង ឈ្មោះដាង ប្ដីគាត់និយាយរួមពីដើមធ្វើក្រសួងការបរទេស ដាងហ្នឹង តែគាត់ស្លាប់ហើយ កាលហ្នឹងទៅស្លាប់នៅអន្លង់វែង ទើបតែឈឺដែរ ។

ដានី ៖ យ៉ាងម៉េចបានជាគេផ្ញើរឲ្យមើលគាត់ ប្រពន្ធគាត់ធ្វើប្រធានសមាគមន៍នារីយ៉ាងម៉េច ព្រោះកាលហ្នឹងក្រែងខាងរដ្ឋកម្ពុជាគេអ្នកគ្រប់គ្រង?

សាន ៖ អត់ទេ កាលហ្នឹងខ្មែរក្រហមគ្រប់គ្រង ។

ដានី ៖ ខ្មែរក្រហមគ្រប់គ្រង?

សាន ៖ ព្រោះយើងវៃបែកដល់ស្វាយចេកហើយហ្នឹង យើងវៃបែកស្វាយចេក ដាក់ម៉ាស៊ីនស្រូវតាមនេះ ធ្វើអាងធ្វើអីនេះ មានគោមានអីធ្វើអាង យើងរំដោះបានប៉ុណ្ណេះ យើងនៅជាមួយប៉ាវ៉ា ដល់ម្ភាក់ វៃបែកស្វាយចេក វៃបែកអីអស់ហើយ ដីធំណាស់ ។

ដានី ៖ ដល់អញ្ចឹងពេលហ្នឹង ហង់ ពិន យាយរ៉ុមអីហ្នឹងគាត់មកនៅផ្កាំហើយ?

សាន ៖ គាត់មកនៅជាប្រជាជនសាម័ញ្ញធម្មតា អត់មាននៅជួរកងទ័ព ។

ដានី ៖ ប៉ុន្តែពេលដែលមកនៅផ្កាំហ្នឹងហើយ កាលហ្នឹងពេលប្រជាជន ទៅនៅជាប់ប្រជាជនហើយបានខាងមេៗគេផ្ដាំ ឬក៏គេជូនគាត់មកឲ្យជួបហើយបានបញ្ជូនគាត់មកនៅផ្កាំ?

សាន ៖ ឲ្យមកនៅផ្កាំហ្នឹង ទិញដីទិញអីឲ្យមកនៅផ្កាំហ្នឹង ។

ដានី ៖ គេឲ្យមកនៅផ្កាំហ្នឹង?

សាន ៖ មិនដឹងជាគាត់មកពីខាងណាទេ ខ្ញុំក៏មិនដែលស្គាល់គាត់ដែរ ស្រាប់តែឃើញគេដឹកឥវ៉ាន់ដឹកឡានគាត់ហ្នឹងមកដាក់នៅផ្កាំហ្នឹង គ្រាន់តែប្រពន្ធគាត់ហ្នឹងផាកឡើងប្រជុំៗ ខ្ញុំជាអ្នកជូនគាត់ ប្រពន្ធគាត់ឡើងជួបអៀង សារី ។

ដានី ៖ ជួបពីណាគេ?

សាន ៖ ជួបអៀង សារី មិនដឹងជាគេស្អីទេ ខ្ញុំដឹកតែឡានទៅ ឈរឡានចោលចាំគេទៅ គេចូលទៅក្នុងទៅ គេមានមន្ទីរក្នុងមន្ទីរក្រៅគេ ។

ដានី ៖ ចុះម៉េចដឹងថាទៅជួបជាមួយអៀង សារី?

សាន ៖ ព្រោះខ្ញុំជាអ្នកជូនទៅ ។

ដានី ៖ ពូឃើញអៀង សារីដែរ?

សាន ៖ ខ្ញុំធ្លាប់ដេកយាមគាត់នៅក្បាលលាវ ប្រពន្ធគាត់ក៏ខ្ញុំធ្លាប់ដេកយាម ។

ដានី ៖ ប្រពន្ធពីណាគេ?

សាន ៖ ប្រពន្ធអៀង សារី អៀង ធារិទ្ធហ្នឹង ខ្ញុំធ្លាប់យាមនៅហ្នឹងឯង យាមផ្ទាល់ ក្នុងមួយយប់យាមតែ៤នាក់ទេ ក្នុងម្នាក់២ម៉ោងគឺបាត់អត់បានទេ យាមអញ្ចឹងគាត់សរសេរឈ្មោះយើង តែគាត់ងើបគាត់ហៅឈ្មោះ ។

ដានី ៖ ប្រពន្ធគាត់អ្នកហៅ?

សាន ៖ ប្រពន្ធងើបក៏ហៅ ប្ដីងើបក៏ហៅ ព្រោះយើងអ្នកយាមនៅជាប់កន្លែងគាត់ហ្នឹង ។

ដានី ៖ គាត់ហៅក្រែងលោបាត់យើង?

សាន ៖ មនុស្សនៅក្រៅផ្សេង តែជំនិតតែ៤នាក់ទេដែលត្រូវយាម ។

ដានី ៖ ពូយាមនៅក្នុងជំនិតនោះដែរ?

សាន ៖ ក្នុងនោះខ្ញុំមួយដែរ ព្រោះខ្ញុំនិរសាកងពល ឡុង ថែម នឹងអៀង សារីហ្នឹងជំនិតបំផុត ៥១៩ហ្នឹងគឺមានតែឡុង ថែម មួយទេដែលជំនិតជាមួយអៀង សារី សូ ហុង យើងថាខណៈខាងលើទេណា៎ ប៉ុន្តែបើនិយាយពីលំដាប់កងពលវិញគឺមានតែឡុង ថែម នឹងអៀង សារីទេ ។

ដានី ៖ ឡុង ថែម ហើយនឹងអៀង សារី?

សាន ៖ បាទ! ជាកូនធម៌ជាអីរបស់គាត់ ចិញ្ចឹមពីតូចមក ហើយឡើងកងពលឡើងអីក៏ដោយសារអៀង សារី ។

ដានី ៖ ដល់ពេលពូ និរសារជំនិតរបស់ឡុង ថែម?

សាន ៖ ខ្ញុំហ្នឹងផ្ទាល់របស់ឡុង ថែម ។

ដានី ៖ ដល់អញ្ចឹងគាត់ឲ្យ?

សាន ៖ ក្នុងម៉ាកងខ្ញុំហ្នឹងមានតែកងមួយហ្នឹងឯងដែលចូលក្នុងនោះបាន ចូលទៅបោសកន្លែងបោសអីឲ្យគេអញ្ចឹងមានតែខ្ញុំ លើកបាយលើកទឹកអីឲ្យ ។

ដានី ៖ ចុះឡុង ថែម គាត់មានធ្លាប់ប្រាប់ពូថាម៉េចខ្លះដែលទាក់ទងនឹងហង់ ពិន ហើយនឹងទាក់ទងយាយរ៉ុម ។

សាន ៖ បើនិយាយរួមទៅគាត់គ្រាន់តែប្រាប់ថា ឲ្យមើលតាហ្នឹងផង ហើយគ្រាន់តែគាត់ថាបើប្រើអីគឺយាយហ្នឹងតាហ្នឹងគាត់ទំនាក់ទំនងអីគឺខ្ញុំមិនដឹងទេ ខ្ញុំដឹងតែយកឡានឡុង ថែម ហ្នឹងឯង

ទៅយក គាត់អត់ដែលនិយាយអីប្រាប់ទេ អត់ប្រាប់ថាមនុស្សនេះមកពីណាៗទេ ដល់ឆ្នាំ ១៩៩៣នេះអ៊ុន គាក់ ចូល ខ្ញុំហ្នឹងទៅភ្នំពេញមុនគេ កាលហ្នឹងគេមិនទាន់ដកអាវុធទេ ខ្ញុំហ្នឹងឡើងទៅភ្នំពេញ ដល់ពេលឡើងទៅភ្នំពេញខ្ញុំទៅលេងគុកទួលស្លែង ដល់ពេលទៅលេងគុកទួលស្លែងទៅឃើញអាក្បាលមេក្រុគាត់និយាយណា៎ កាលហ្នឹងជំនាន់ហ្នឹងគាត់ចោរប្លន់ ហើយគាត់ទៅនៅស្វាយចេក ដល់ពេលខ្ញុំទៅឃើញថាតា ខ្ញុំចង្អុលមុខអញ្ចឹង ខ្ញុំឃើញតាឯងនៅគុកទួលស្លែង និយាយក្បាលមេក្រូ គាត់ជេរខ្ញុំអារបស់យោកុំមាត់ៗ

ដានី ៖ តាណា?

សាន ៖ តាពិន ហ្នឹង គាត់ជេរខ្ញុំអារបស់យោកុំមាត់ ហើយខ្ញុំទៅគុកទួលស្លែងហ្នឹងខ្ញុំឃើញគាត់មុនគេ ឃើញរូបនៅក្នុងគុកណា៎ ដល់ពេលខ្ញុំមកវិញខ្ញុំថា តា តាឯងខ្ញុំឃើញក្នុងគុកទួលស្លែងទាំងខ្មោចយាយទាំងអីនៅហ្នឹងទាំងអស់ ក្បាលមេក្រូឡើងច្រុះ តាឯងនិយាយមាត់ឡើងស្រួច គាត់វៃក្បាលខ្ញុំ ថាអារបស់យោឯងកុំមាត់ ឯងកុំនិយាយណារបស់យោ គាត់ជេរខ្ញុំអញ្ចឹង ដល់ពេលក្រោយមកគាត់ទៅសម្លុតទៅអីទៅ ព្រោះតែគេចាប់ខ្លួនគាត់ ដាច់រយៈតាំងពីហ្នឹងមក គ្រាន់តែដឹងច្បាស់ថារបស់របរគាត់ទាំងអស់ហ្នឹង គាត់ប្រើសុទ្ធតែរបស់សៀងហៃ នាឡិការអីហ្នឹងសុទ្ធតែត្រាសៀងហៃទាំងអស់ ជញ្ជៀនក៏វៃត្រាសៀងហៃ ជញ្ជៀនមាសគាត់ៗ

ដានី ៖ ម៉េចបានគាត់ប្រើរបស់សៀងហៃ?

សាន ៖ មិនដឹង ព្រោះគាត់មិនមែននៅចិនណា គាត់ទិញរបស់សៀងហៃយកមកប្រើៗ

ដានី ៖ គាត់ធ្លាប់ទៅនៅចិន?

សាន ៖ គាត់នៅចិនៗ

ដានី ៖ ពូដឹងថាគាត់ទៅឆ្នាំណាទេ?

សាន ៖ អត់ដឹងឆ្នាំណាទេ តែគ្រាន់តែមេខ្ញុំប្រាប់ថាគាត់ហ្នឹងធ្លាប់ទៅចិន ក្រោយពី៧៩មកហ្នឹងគាត់អត់នៅទេ គាត់ទៅចិនៗ

ដានី ៖ អញ្ចឹងក្រោយពីបែក៧៩ភ្លាម ពេលដែលយួនចូលហ្នឹងគាត់អត់បាន?

សាន ៖ គាត់អត់បាននៅតស៊ូជាមួយគេ ស្ពាយអាវុធស្ពាយអីទេ អត់ដែលឃើញទេ ហើយឆ្នាំដែលគេវៃបែកប៉ៃលិនគគ្រឹកគគ្រេងហ្នឹងមក មេៗមកនៅភ្នំឆ័ត្រហ្នឹងបានឃើញមុខគាត់ហ្នឹង កាលហ្នឹងមានតាំងពីប៉ុល ពត អីនៅហ្នឹងទាំងអស់ នៅភ្នំឆ័ត្រយើងហ្នឹង ធ្វើផ្ទះហ្នឹងយកដាងពីនេះទៅ អ្នកស្រុកនេះឯងធ្វើដាងឲ្យ ទៅធ្វើផ្ទះតាមរយៈឡុង ថែម ទាំងអស់ដឹកទៅពី

នេះ ដឹកទាំងឡានទៅធ្វើដាងទៅធ្វើផ្ទះឲ្យ និយាយរួមទៅអៀង សារី ហើយនឹងសូ ហុង ហ្នឹងគាត់ទុកចិត្តតែឡុង ថែមទេ អ្នកណាដែលមនុស្សរបស់ឡុង ថែម ហ្នឹងគឺទៅធ្វើផ្ទះនៅបានទាំងអស់ ។

ដានី : ដល់ពេល ពូដឹងថាគេចាត់ ថ្នាក់លើគេចាត់គាពិនហ្នឹងឲ្យមកនៅផ្កាំហ្នឹង?

សាន : ខ្ញុំដឹងតាមរយៈឡុង ថែម ហ្នឹង ។

ដានី : ដឹងមូលហេតុម៉េចបានដាគេឲ្យគាត់មកនៅ?

សាន : អត់ដឹងផង ជំនាន់នោះបើនិយាយរួមទៅ ដូចថាយើងហ្នឹងចង់ឲ្យប្រជាជនអីមានមុខរបរជាលុយជាកាក់អីឲ្យប្រជាជនខ្ញី អញ្ចឹងគាត់មកឈរជើងហ្នឹងឯង ។

ដានី : ចង់មានមុខរបរឲ្យប្រជាជនខ្ចី?

សាន : ខ្ចីលុយទិញគោ ទិញអីហ្នឹង ។

ដានី : ខ្ចីពីពីណា?

សាន : ខ្ចីពីសមាគមន៍គេហ្នឹងឯង សហគមន៍គេហ្នឹង ។

ដានី : ខ្ចីសមាគមន៍ សហគមន៍ដែល?

សាន : ខ្មែរក្រហមគេទម្លាក់ឲ្យមក ប៉ុន្តែមានយាយមឿន ហ្នឹងមួយ មានគាត់ហ្នឹងមួយ គេថាអ្នកគ្រប់គ្រងបញ្ជី ។

ដានី : ចុះកាលហ្នឹងប្រជាជនខ្ចីលុយគាត់អត់?

សាន : មានច្រើនណាស់ ខ្ចីរាប់លាន ខាងពន្លៃហ្នឹងច្រើនជាងហ្នឹងទៀត ខាងនោះតាសីអ្នកគ្រប់គ្រង តាសី ហ្នឹងគាត់ស្លាប់ហើយ ។

ដានី : ដល់ពេលខាងផ្កាំហ្នឹងប្រពន្ធគាពិន យាយរ៉ុម ហ្នឹងគ្រប់គ្រង?

សាន : បាទ!

ដានី : មានខ្ចីទិញមេគោទិញអី?

សាន : បាទ! ទិញគោ ទិញអី ដល់ក្រោយពីអន្តការរបស់ខ្មែរក្រហមរលំទៅមានអ្នកណាសងនិយាយរួមទៅកាលហ្នឹងគេថាតំបន់រំដោះ ធ្វើម៉េចឲ្យប្រជាជនធូរធារ លែងឲ្យខ្ចីអស់ច្រើនណាស់លុយ ។

ដានី : ទិញមេគោទិញអីទៅ?

សាន : បាទ! ទិញជាមេគោ ទិញជាអីទៅលុយហ្នឹង ។

ដានី : ចុះបើតាមពូចាំ ពូធ្លាប់យកឡានទៅដឹកគាត់ទៅជួបអៀង សារី ប៉ុន្មានដងដែរ?

សាន ៖ ជួបប្រហែលជា៣-៤ដងដែរមកនៅហ្នឹង ខ្ញុំដឹងអាស៊ីបចិនគេបើកឲ្យមួយ ។

ដានី ៖ ដឹកពីកន្លែងណាទៅកន្លែងណា?

សាន ៖ ដឹកពីផ្ទះគាត់ទៅជួបគាត់ ។

ដានី ៖ ដឹកពីផ្ទះគាត់នៅផ្ការំហ្នឹង?

សាន ៖ បាទ! ទៅយកដល់ផ្ទះ ។

ដានី ៖ ទៅតែគាត់ទេ?

សាន ៖ ទៅតែឯង គាត់អត់មានប្តីអីទៅជាមួយទេ ។

ដានី ៖ គាពិន អត់ទៅជាមួយទេ?

សាន ៖ អត់ទេ ទៅតែយាយហ្នឹងម្នាក់ទេ ហើយជិះឡានជាមួយខ្ញុំហ្នឹងក៏គាត់មិនដែលនិយាយពីប្រវត្តិស្អីឲ្យស្តាប់ដែរ អត់ទេ អត់ទាំងអស់ ដឹងតែយើងជូនទៅគេថាចូលមន្ទីរក្នុងទៅយើងនៅចាំទៅ ។

ដានី ៖ ចូលទៅមន្ទីរក្នុង?

សាន ៖ បាទ! គេចប់ទៅយើងដឹកចេញមកវិញមក ។

ដានី ៖ ដឹកតែគាត់ម្នាក់ទេ?

សាន ៖ ដឹកតែម្នាក់ ។

ដានី ៖ ហ្នឹងតាឡុង ថែម អ្នកប្រាប់ឲ្យដឹក?

សាន ៖ គាត់អ្នកបញ្ជាឲ្យខ្ញុំទៅយក ។

ដានី ៖ ឲ្យទៅយក៣-៤ដង អាហ្នឹងឆ្នាំណាខ្លះ?

សាន ៖ មិនបានចាំដល់ពេលអញ្ចឹង ។

ដានី ៖ កាលគាត់មកនៅហ្នឹងឆ្នាំ៩០-៩១?

សាន ៖ ៩១-៩០នេះឯង ។

ដានី ៖ ហើយបើតាមអំឡុងដឹកហ្នឹងប្រហែលជាខ្ទង់?

សាន ៖ វាជួនកាលទៅម៉ាឆ្នាំដឹកពីរដើង ។

ដានី ៖ ក្នុងឆ្នាំហ្នឹងដដែល?

សាន ៖ បាទ! ក្នុងឆ្នាំហ្នឹង ។

ដានី ៖ មុនអ៊ុន គាក់មក?

សាន ៖ មុនអ៊ុន គាក់មក ដល់ពេលជំនាន់អ៊ុន គាក់ មកបែកហើយ បែកគ្នាហើយ គាត់ហ្នឹងគេចោរប្ញន់គាត់មុនអ៊ុន គាក់មក គាត់ក៏ទៅនៅស្វាយចេក កាលហ្នឹងស្រុកវាស្រួលហើយ យើងទៅនៅកន្លែងណាក៏បានដែរ គេដកកាំភ្លើងរបស់ខ្មែរក្រហមអស់ហើយ បែកគ្នាចប់កាលអ៊ុន គាក់មក ។

ដានី ៖ អញ្ចឹងពេលអ៊ុន គាក់ ចូលមកបែកគ្នាហើយ?

សាន ៖ បែកគ្នាហើយ គេដកកាំភ្លើងអស់ហើយ អាខ្លះទៅស្រុក អាខ្លះនៅ ដល់ពេលខ្ញុំមិនដឹងទៅណាមានតែពួននៅហ្នឹងទៅ ។

ដានី ៖ ពូការឆ្នាំណា?

សាន ៖ ៨៩ វេីបែកស្វាយចេក ។

ដានី ៖ វេីបែកស្វាយចេក៨៩ ការនៅហ្នឹងហ្មង?

សាន ៖ ការនៅហ្នឹងឯង នៅផ្ទះក្រោយហ្នឹងការ ។

ដានី ៖ ចុះចំពោះតាពិន វិញ ពូខស្សាហ៍ជួបគាត់ ដឹកគាត់អីយ៉ាងម៉េចដែរ?

សាន ៖ បើនិយាយពីរឿង តាពិន វិញអត់ដែលបានដឹកតាពិនម្តងណាទេ ដឹកតែប្រពន្ធ ។

ដានី ៖ ដឹកប្រពន្ធ?

សាន ៖ បាទ! បើទៅចេញចូលផ្ទះគាត់និយាយធម្មតា យើងអ្នកស្រុកធម្មតា គាត់ចិញ្ចឹមគោ ចិញ្ចឹមមាន់ ចិញ្ចឹមទាធម្មតា និយាយរួមទៅប្រជាជនយើងសាម័ញ្ញ ហើយគាត់ធ្វើជាគ្រូបង្រៀននៅផ្កាំហ្នឹងឯង ។

ដានី ៖ ធ្វើគ្រូបង្រៀន?

សាន ៖ ហ្នឹងអើយ ។

ដានី ៖ ដឹងថាយ៉ាងម៉េចបានជាគាត់ធ្វើគ្រូបង្រៀន គេបញ្ចូលគាត់?

សាន ៖ ដូចថាគេឃើញគាត់អ្នកចេះ កាលហ្នឹងមនុស្សអត់មានអ្នកណាចេះផង គេបង្កើតសាលា កាលយើងនៅក្មេង កាលហ្នឹងប៉ុរ៉ាគេធ្វើសាលាឲ្យ ដល់គាត់ហ្នឹងមិនដឹងជាយ៉ាងម៉េចបានជាចូលតាមរយៈគ្រូ ដូចថាគាត់ហ្នឹងបង្រៀនកូនក្មេងណា៎ ដល់បង្រៀនកូនក្មេងទៅបែកគេយកគាត់ធ្វើគ្រូ បើនិយាយរួមទៅដីនេះគ្មានអ្នកណាដឹងប្រវត្តិគាត់មួយទេ ព្រោះគាត់អត់មានដែលនិយាយប្រាប់អ្នកណាទាំងអស់ ថ្នាក់លើក៏មិនដែលថាតានេះមកពីណាដែរ អត់ដែលផ្សព្វផ្សាយទាំងអស់ និយាយរួមទៅបិទជិតឈឹងហ្មង ។

ដានី : អញ្ចឹងកាលពីនៅភ្នំឆ័ត្រ ភ្នំប្រាក់អីហ្នឹង កាលហ្នឹងតាពិនហ្នឹងក៏គាត់ធ្លាប់ទៅជួបអី នៅជាមួយ?

សាន : បើនិយាយរួមទៅកាលនៅភ្នំឆ័ត្រហ្នឹង ភ្នំប្រាក់ហ្នឹងអត់ដែលឃើញមុខគាត់ផង ស្រាប់តែមកឃើញនៅផ្កាំហ្នឹងហ្នង អត់ដែលមានផ្ទះនៅភ្នំឆ័ត្រភ្នំប្រាក់អីទេ មិនដឹងជាគេយកមកពីខាងណា ហើយស្រាប់តែមកនៅហ្នឹងហ្នង ។

ដានី : តែមកនៅនេះមិនមែនមកចិត្តឯងទេ?

សាន : មិនមែនទេ ។

ដានី : គេបញ្ជូនមក?

សាន : គេបញ្ជូនមក បើមិនបញ្ជូនមកគាត់មានលទ្ធភាពអីបញ្ជាយើងឲ្យដឹក សុទ្ធតែថ្នាក់កងពលជូនអញ្ចឹង ខ្ញុំចាប់អារម្មណ៍ដែរថាយាយហ្នឹងម៉េចក៏ខ្លាំងម្ល៉េះ ហើយយាយហ្នឹងអាក្រក់ ខ្មៅក្រញ៉េះ ហើយមាឌធំ សក់ឡើងកន្ទ្រើងដូចប្រុស គាត់ហ្នឹងប្រពន្ធតាឌុចនេះអាក្រក់ណាស់មនុស្ស ខ្មៅព្រឹច ។

ដានី : អ្នកស្រុកណាទៅមើលទៅ?

សាន : អត់ដឹងប្រវត្តិដែរ ។

ដានី : អត់ដឹងប្រវត្តិ?

សាន : បាទ! ហើយខ្ញុំថាយាយហ្នឹងម៉េចក៏ថ្នាក់កងពល ម៉េចក៏ខ្លាចគាត់ នឹកក្នុងចិត្តណា៎ បញ្ជាឲ្យឯងហ្នឹងដឹកត្រម៉ាត់ត្រម៉ែង យាយហ្នឹងមកពីខាងណា នឹកក្នុងចិត្តដែរ គ្រាន់តែមិនដឹងប្រវត្តិសូម្បីតែមេខ្ញុំហ្នឹងមិនដែលនិយាយប្រវត្តិឲ្យគាត់ស្តាប់ផង ។

ដានី : ចុះសម្លៀកបំពាក់គាត់ គេស្លៀកសម្លៀកយ៉ាងម៉េចដែរ?

សាន : ប្រជាជនយើងធម្មតា អត់ដែលមានស្លៀកខោអាវខ្មែរក្រហម សូម្បីតែអាវុធមិនដែលមានផងផ្ទុះគាត់ ។

ដានី : អត់ដែលមានទេ?

សាន : ប្រជាជនសុទ្ធ និយាយម៉ាមកនៅហ្នឹងប្រជាជនសុទ្ធ គ្រាន់តែផ្ទៃក្នុងរបស់គេមិនដឹងជាស្អីសូម្បីតែចោរប្លន់ ប្រពន្ធគាត់ស្លាប់ក៏ដោយ ខ្មែរក្រហមក៏ដូចជាមិនឈឺឆ្អាលរឿងរបស់គាត់ស្លាប់ ។

ដានី : ម៉េចអញ្ចឹង?

សាន ៖ ដូចជាអត់មានអ្នកណាស្រាវជ្រាវផង ដូចថាមិនមានអ្នកណាឈឺឆ្អាលថាអាណាមកប៉ុន្មានអញ្ចេះអញ្ចុះទេ អត់មានទេ មិនដឹងជារឿងម៉េចអត់ដឹងដែរ ។

ដានី ៖ ដល់ពេលឆ្នាំណាដែលពូនិយាយម៉េញថា ពូអញ្ជើញទៅទួលស្លែង ថាអញ្ជើញទៅភ្នំពេញ?

សាន ៖ អ៊ុន គាត់ ចូលភ្នាមខ្ញុំប្រុយ គេដកកាំភ្លើងហើយទៅហ្នឹង ។

ដានី ៖ ទៅយ៉ាងម៉េច ទៅលេងឬក៏?

សាន ៖ ទៅលេង គេថាទួលស្លែងៗក៏ទៅមើលនឹងគេទៅ ហើយឃើញគាត់ហ្នឹង ដល់ពេលឃើញគាត់មកវិញជួបនៅផ្សារថ្មីយើងស្វាយនេះ គាត់ជិះម៉ូតូឌុបមក ខ្ញុំចង្អុលមុខ តា ក្រែងតាឯងនៅគុកទួលស្លែង គាត់ជេរខ្ញុំអារបល់យោ ឯងកុំមាត់ គាត់និយាយតែមួយម៉ាត់ប៉ុណ្ណឹងឯង ។

ដានី ៖ ហើយដែលនិយាយប្រាប់គេទៀតទេ?

សាន ៖ អត់ ដល់ពេលអញ្ចឹងទៅ ខ្ញុំក៏ថា អេ៎! តាហ្នឹងធ្វើស្អីបានជាក្បាលមេក្រូច្រើនម្លេះ នឹកក្នុងចិត្ត ព្រោះជំនាន់នោះប្រពន្ធគាត់ឈរពីក្រោយបង់កក្រម៉ា ហើយមានរូបថតមួយសន្លឹកទៀត គេធ្វើធំរូបថតហ្នឹង ម៉ាក្រុមគ្រួសារគាត់កូនគាត់ទាំងអស់ឈរម៉ាក្រុមគ្រួសារគាត់មួយសន្លឹកទៀត ហើយអាគាត់ប្រជុំក្បាលមេក្រូ៨-១០-២០ ហើយនឹងប្រពន្ធគាត់មួយសន្លឹក ធំៗណាស់ ខ្ញុំមើលឃើញខ្ញុំចាំច្បាស់ បើមកខ្ញុំថាឲ្យគាត់ទៀត ប្រពន្ធគាត់ស្លាប់អស់ហើយ បានគាត់ថាឯងកុំមាត់ណាអារបល់យោ ហើយក្រោយពីហ្នឹងមកដែលគាត់ទៅនៅសាលារៀននៅអី នៅស្វាយចេកអីហ្នឹង និយាយរួមទៅថ្នាក់ដឹកនាំខ្មែរក្រហមទាំងអស់គឺគាត់ទៅនៅកន្លែងណាគឺគ្មានអ្នកណាមួយទៅជិត និយាយរួមគឺក្នុងជួរខ្មែរក្រហមគឺអត់មានទៅទំនាក់ទំនងអីជាមួយគាត់ទេ សូម្បីតែពួកខ្ញុំហ្នឹងមិនដឹងជាផ្ទះគាត់នៅស្វាយចេកហ្នឹងម៉េចផង ដូចថាគេចាត់ទុកថាមនុស្សម្នាក់ហ្នឹងមិនដឹងថាមកពីខាងណា គ្មានអ្នកណាដឹងប្រវត្តិទេ ថ្នាក់វរៈសេនាធំ កងពលក៏ដោយក៏មិនដឹង បើនិយាយរួមទៅអត់ដឹងប្រវត្តិ ហើយអ្នកដែលថាជិតដិតជាមួយគាត់ ធ្លាប់រស់នៅជាមួយគាត់ ក្រោយពីស្រុះស្រួលហើយក៏មិនដែលទៅសួរនាំគាត់ថា តាឯងសុខសប្បាយឬក៏មិនសុខសប្បាយគឺអត់ហ្នឹង អត់មានហ្នឹង អត់មានទំនាក់ទំនង លើកលែងតែជួបគ្នាតាមផ្លូវអញ្ចឹង ឯងទៅណាមកណា តាឯងនៅណា សុខសប្បាយអត់ អាហ្នឹងបានសួរនាំគ្នា បើរឿងសួរនាំគ្នានៅតាមផ្ទះគឺគាត់មិនដែលទៅផ្ទះគេ ហើយគេក៏មិនដែលទៅផ្ទះគាត់ វាចម្លែកត្រង់ហ្នឹងឯង អញ្ចឹងបានថាយើងអត់ស្គាល់ប្រវត្តិគាត់ ហើយយើងអត់បានទំនាក់ទំនង សូម្បីតែអ្នកផ្ទាំហ្នឹងមិនដឹងថាគាត់ធ្វើអីផង នៅជាប់

របងហ្នឹងសួរមើល  អត់មានដឹងទេ  អត់មានដឹងថាអ្នកណាធ្វើអីៗទេ  និយាយរួមទៅអ្នកដែលដឹងគឺមានតែខ្ញុំទេដឹងជ្រៅជាងគេបន្តិច  ព្រោះខ្ញុំដឹកប្រពន្ធគាត់  ខ្ញុំដឹងប្រពន្ធគាត់អ្នកធ្វើការបានជាកងពលបញ្ជាឲ្យខ្ញុំដឹក  បើសម្រាប់អ្នកផ្ទាំអត់ដឹងទាំងអស់ ។

ដានី :  ចុះកាលហ្នឹងឡានបើកកើតដែរពីផ្ទាំទៅ?

សាន :  បើកបានទាំងអស់  ផ្លូវដីខ្សាច់ ។

ដានី :  ដីខ្សាច់?

សាន :  អាស៊ីបចិនធ្លាក់អាងហ្នងម្ដង  អ្នកស្រុកគាស់ទាំងភូមិ  ដឹកគ្រាប់ដឹកអី  ការខ្ញុំដឹកទឹកកកពីថៃទាំងអស់  ការខ្ញុំនៅនេះឯង  ការហ្នឹងស្មៀកពាក់ខោអាវខ្មែរក្រហមទៀត  ពាក់ក្នុងយើងធម្មតាតែខោអាវខ្មែរក្រហម  គេឲ្យខ្ញុំការធ្វើជាឯកសារ  ព្រោះខ្ញុំមានប្រវត្តិបងខ្ញុំហ្នឹងខាងគណៈទាក់ទងថៃ-ខ្មែរ  ឥឡូវធ្វើចៅអធិការវត្តភាស  បើចង់សួរនាំអីដឹងរឿងច្រើនណាស់ ។

ដានី :  គាត់នៅវត្តណា?

សាន :  វត្តភាស  ចៅអធិការ  ដឹងរឿងច្រើនណាស់ព្រោះគាត់ទំនាក់ទំនងថៃ-ខ្មែរ ។

ដានី :  វត្តភាស?

សាន :  ពីភ្នំដងរែកមកដល់យើងព្រៃមាន់នេះ  មុខសញ្ញារបស់គាត់ ។

ដានី :  វត្តភាសហ្នឹងនៅក្នុងភូមិឃុំអី?

សាន :  ឃុំសារោះ ។

ដានី :  គាត់បួសឆ្នាំណា?

សាន :  បួស៥វស្សាហើយ ។

ដានី :  ៥វស្សាហើយ?

សាន :  ២០០៤-២០០៥  ចូល៦វស្សាហើយ ។

ដានី :  ចុះម៉េចបានជាគាត់បួស?

សាន :  គាត់ក្រោយពីយើងបែកបាក់គ្នាមក  គាត់ពីដើមធ្លាប់មាន  គាត់កាន់លុយទាំងគីឡូ  ដល់ពេលចូលមកអាសន្កមយើងនេះទៅវាមានផ្លាសផ្លាសទៅ  ចេះតែនេះក៏គាត់បួសទៅ ។

ដានី :  គាត់អាយុប៉ុន្មានហើយ?

សាន :  អាយុ៥០លើសហើយ ។

ដានី :  គាត់មានប្រពន្ធកូនទេ?

សាន ៖ ប្រពន្ធកូនគាត់នៅហ្នឹងឯង ប្រពន្ធដើមគាត់ពីដើមនៅក្នុងក្រសួងការបរទេស ប្រពន្ធគាត់នៅជាមួយអៀង សារីហ្នឹង លើកបាយលើកទឹកអី និយាយរួមអ្នកបម្រើអ្នកធំណា៎ ហើយគាត់បានគ្នាទៅ ដល់បែកបាក់ជាមួយប្រពន្ធ និយាយរួមទៅគាត់ខូចចិត្ត ប្រពន្ធគាត់ផិត ។

ដានី ៖ បែកបាក់ក្រោយហ្នឹងបុក៏យ៉ាងម៉េច?

សាន ៖ បែកបាក់កាលនៅសង្គ្រាមហ្នឹងឯង ដល់ហើយគាត់យកប្រពន្ធមួយទៀត មនុស្សខូចចិត្តឥឡូវចៅអធិការហើយ ធម៌អាលាយហើយ ទៅប្រជុំនៅបាំងកកថៃអាលាយ មើលអក្សរថៃចេញខ្មែរ ព្រោះគាត់នៅក្រសួងការបរទេសហើយ ។

ដានី ៖ ដល់ពេលក្រោយមកគាត់នៅកងពល៥១៩?

សាន ៖ ប្រចាំការនៅ៥១៩ គាត់នៅតាំងពីដងរែកមករហូតមក ២កន្លែង អាក្បាលលាវមួយកន្លែងហើយភ្នំត្រមួយកន្លែង ផ្ទះគាត់នៅម៉ាឡៃ ។

ដានី ៖ ផ្ទះគាត់នៅម៉ាឡៃ?

សាន ៖ នៅភូមិដូង ។

ដានី ៖ ខ្ញុំទៅដែរហ្នឹង ខ្ញុំទៅជួបតាជៀម ។

សាន ៖ តាជៀមហ្នឹងសុទ្ធតែគ្នាគាត់ហើយ តានី កំបុតជើងហ្នឹងសុទ្ធតែគ្នាគាត់ទាំងអស់ហ្នឹង តាម៉ុកយើងហ្នឹង ។

ដានី ៖ អញ្ចឹងពូដល់ពេលឆ្នាំ៩៣ហ្នឹង យើងលែង?

សាន ៖ លែងទំនាក់ទំនង ។

ដានី ៖ អញ្ចឹងពូឆ្នាំ៩៣នៅធ្វើកងទ័ពទៀតកបុក៏យ៉ាងម៉េច?

សាន ៖ ៩៣ហ្នឹងគេប្រកាសបញ្ចូលទៅ ចូលក្នុងកងខេមរភូមិន្ទ ប្រកាសចូលអាវគ្គក្រោយ៩០ប៉ុន្មានក្រោយទៀត ៩៣ឈប់មួយរយៈហើយ ដល់ពេលប្រទុះប្រទះប៉ារ៉ាដកអាវុធទៅបានវៃប៉ារ៉ាមួយសារទៀត ដល់ពេលវៃមួយសារទៀតទៅបានគេផ្តាច់ខ្លួនមកហ្នឹងបានចូលជាខេមរភូមិន្ទ ។

ដានី ៖ ចូលពីឆ្នាំណាមក?

សាន ៖ ខេមរភូមិន្ទចូលពីឆ្នាំប៉ុន្មានទេ ដូចជា៩៧ ផ្តាច់ខ្លួន៩៧ ។

ដានី ៖ ចុះម៉េចបានជាពូឈប់នៅជាមួយឡុង ថៃម?

សាន ៖ នៅរហូតទាល់តែគាត់ស្លាប់ គាត់ហ្នឹងចូលមករងភូមិភាគ៤ ខ្ញុំហ្នឹងខេមរភូមិន្ទហ្នឹងឯង ដល់គាត់ក្រោយមកទៅក្រសួងការបរទេសទៅ ពួកខ្ញុំកាត់បញ្ចូលកងពល ។

ដានី ៖ ឡុង ថៃម ហ្នឹងគាត់ទៅ?

សាន ៖ គាត់ទៅខាងក្រសួងការបរទេស ។

ដានី ៖ ក្រសួងការបរទេសនៅភ្នំពេញ?

សាន ៖ អាស៎ ទៅក្រសួងការពារជាតិ ។

ដានី ៖ ទៅភ្នំពេញទៅ?

សាន ៖ ឈ្មោះនៅភ្នំពេញ ជាមួយខុល សារឿន គេប្រូបាច់បញ្ចូលហ្នឹង ក្រសួងការពារជាតិ មានកម្លាំងមកពីណាមានតែឈ្មោះទៅ កម្លាំងគេប្រូបាច់បញ្ចូលកងពល ដល់ក្រោយមកគេប្រូបូកប្រូបល់គ្នាកាត់ទៅស៊ុបទៅអីទៅ ខ្ញុំជាប់ទៅខាងស៊ុប ។

ដានី ៖ អញ្ចឹងតាឡុង ថៃម ហ្នឹងគាត់ស្លាប់ហើយ?

សាន ៖ គាត់ស្លាប់ហើយ ក្រឡាប់ឡាននៅត្រពាំងសានជាមួយព្រំ ស៊ូ តែព្រំ ស៊ូ បែកមុខបែកមាត់តែអត់អី គេហៅគោផ្កាយបីៗហ្នឹង ។

ដានី ៖ គាត់ក្រឡាប់ខ្លួនឯងឬក៏មានបញ្ហា?

សាន ៖ ក្រឡាប់ខ្លួនឯង គេកាយផ្លូវថ្មី តែផ្លូវគេឡើងចុះអញ្ចឹងទៅ ។

ដានី ៖ គាត់បើក?

សាន ៖ គាត់បើកខ្លួនគាត់ ពីដើមមកខ្ញុំអ្នកបើក ដល់ពេលខ្ញុំទៅអត់ទាន់គាត់ប្រញ៉ាប់ជូនអ្នកអាមេរិចមួយទៅអន្លង់វែងហ្នឹងឯង ដល់ពេលផ្លូវគេកាយថ្មីមានផ្លូវវាងមួយ ផ្លូវវាងមានឡាននីសសាន់ដឹកឈ្នួលគេវាងបានមុនគាត់លាអត់ត្រង់ ឡង់គ្រីស័រដាច់ប្រាំង ។

ដានី ៖ តែ២នាក់គាត់?

សាន ៖ ៣នាក់ អ្នកអាមេរិចមួយ ។

ដានី ៖ ស្លាប់ប៉ុន្មាននាក់?

សាន ៖ ស្លាប់តែឯង គាត់ជាប់ខ្សែក្រវ៉ាត់ ជាប់ចង្កូតយើងហ្នឹង អាក្របូរវាហ្នឹងរុញមកបុក ។

ដានី ៖ ព្រំ ស៊ូ អត់អីទេ?

សាន ៖ ព្រំ ស៊ូ អត់អីទេ បែកកញ្ចក់គាត់វាចេញរួច ដល់បែកមុខបែកមាត់អស់ ។

ដានី ៖ ឆ្នាំណាដែលគាត់ស្លាប់ហ្នឹង?

សាន ៖ ឆ្នាំដូចជាចូល២០០១-២០០២ហើយ ។

ដានី ៖ កាលហ្នឹងពូនៅជាមួយគាត់នៅឡើយទេ?

សាន ៖ ខ្ញុំនៅជាមួយគាត់ ។

ដានី ៖ ដល់ពេលក្រោយមកគាត់កាត់ពូទៅនៅស៊ុបហ្នឹង?

សាន ៖ បាទ!

ដានី ៖ ឥឡូវអត់សូវទៅធ្វើការទេ?

សាន ៖ មួយខែទៅ២-៣ថ្ងៃ ព្រោះទៅមិនដឹងធ្វើអីផង ។

ដានី ៖ អត់មានការងារធ្វើទេ?

សាន ៖ ទាល់តែមានលុយគេបើកមកបានយើងទៅបើកហ្នឹងគេទៅ ហើយយើងមកផ្ទះវិញ ។

ដានី ៖ ពូមកដល់សព្វថ្ងៃពូមានដែលឮ ឬឃើញគេកាត់ទោស តាពិន ហ្នឹងដែរអត់?

សាន ៖ ឃើញ មើលទូរទស្សន៍ឃើញតើ ។

ដានី ៖ ឃើញដែរ?

សាន ៖ ឃើញ ។

ដានី ៖ ពូម៉េចដែរ កាលនោះយើងអត់ដែលដឹងប្រវត្តិគាត់?

សាន ៖ យើងអត់ដឹងប្រវត្តិអញ្ចឹង យើងឆ្ងល់ដែរថា តានេះម៉េចក៏ធំម្ល៉េះ យើងអត់ដឹងគាត់ផង ហើយបើសិនជាយើងហ្នឹងថាកាត់ទោសម៉េច បើយើងខ្មែរក្រហមជាមួយគាត់ដែរ តែមិនដែលឃើញគាត់សម្លាប់អ្នកណាផង មិនដឹងថាម៉េចបានត្រូវបើយើងអត់ដឹង បើយើងធ្វើខ្មែរក្រហមមិនដែលបានសម្លាប់ណាផង ព្រោះយើងសេរីក្រោយ សេរីគេចាស់ ។

ដានី ៖ ពូភ្ញាក់ផ្អើលទេពេលដែលគេកាត់ទោសគាត់ ហើយដល់ពេលដឹងថាគាត់ហ្នឹងប្រធានគុកទួលស្លែង?

សាន ៖ ភ្ញាល់ផ្អើលដែរ ព្រោះយើងវាមិនដែលដឹងសោះ ហើយថាតានេះអញ្ចឹងតើ ប៉ុន្តែខ្ញុំដឹងមុនគេ ខ្ញុំដឹងថាគាត់ហ្នឹងពាក់ព័ន្ធនឹងគុកទួលស្លែង ខ្ញុំបានឃើញមុនគេ ។

ដានី ៖ ពូយល់ឃើញយ៉ាងម៉េចដែរ តុលាការដែលគេកាត់ទោសរាល់ថ្ងៃហ្នឹង ដូចគេកាត់ទោសមេដឹកនាំខ្មែរក្រហម កាត់ទោសដូចថាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើងធ្ងន់ធ្ងរពីសម័យហ្នឹងដូចជា ឌុច អីហ្នឹង ។

សាន ៖ យល់ឃើញថាយើងធ្វើខាងហ្នឹងហើយ មិនដឹងយល់ឃើញយ៉ាងណា ។

ដានី ៖ ឧបមាថាយល់ឃើញថាអាហ្នឹងវាត្រឹមត្រូវដែរ ឬក៏មិនត្រឹមត្រូវ មូលហេតុអីបានជាមិនត្រឹមត្រូវ មូលហេតុអីបានជាត្រឹមត្រូវ?

សាន ៖ បើយើងនិយាយឲ្យដល់ទៅ ពីសម័យនោះបើនិយាយអាយុប្រហែលខ្ញុំវាថាសឹងតែកើតមិនទាន់ ដូច្នេះសឹងតែដូចថាមិនដឹងរឿង ដល់ពេលយើងធំឡើងដឹងក្តីយើងនៅជាមួយគេ ដូច្នេះ

វាអត់ចាប់អារម្មណ៍ និយាយមួយម៉ាត់ទៅអត់ចាប់អារម្មណ៍ ព្រោះគេគាត់ប្រជាពលរដ្ឋណា គេថាគេឈឺចាប់ឈឺអីព្រោះយើងអត់បានឃើញ យើងទៅស្រែកថាឈឺចាប់ម៉េចកើត បើយើងមិនបានជួបខ្លួនយើងផង គេគាត់ បើគេអ្នកដឹងរឿងគេឈឺចាប់ទៅ ដូចថាយើងអ្នកអត់ឈឺចាប់ទៅអត់ចាប់អារម្មណ៍ គ្រាន់តែបានម៉ាដឹងថាអានេះអញ្ចេះ អានោះអញ្ចុះប៉ុណ្ណឹងឯង តែបើនិយាយពីរឿងខ្លួនឯងវិញអត់មានអារម្មណ៍អីដែលថាឈឺចាប់ជាមួយគាត់ អត់មានអារម្មណ៍ ព្រោះគាត់អត់បានធ្វើអីយើង យើងក៏អត់ដឹងគាត់ ដូច្នេះជារឿងធម្មតា ។

ដានី ៖ ហើយពេលនៅជាមួយគាត់ទៅធម្មតា?

សាន ៖ ហ្នឹងហើយ រឿងរបស់គាត់ ។

ដានី ៖ ពូធ្លាប់អាសារទៅលេងស្រុកទេ ស្រុកកំណើត?

សាន ៖ ទៅមួយឆ្នាំម្តងៗ

ដានី ៖ ឪពុកពូគាត់នៅហ្នឹង?

សាន ៖ គាត់ខូចអស់ហើយ ប៉ុន្តែទៅហ្នឹងបានតែម៉ាដីយើងដីអីហ្នឹងគេយកអស់ហើយ គេអ្នកជម្លៀសមកហ្នឹងគេយកអស់ហើយ ។

ដានី ៖ ចុះបងប្អូនបង្កើត?

សាន ៖ បងប្អូនបង្កើតមកនៅនេះទាំងអស់ ។

ដានី ៖ មកនៅខាងនេះអស់ហើយ?

សាន ៖ បាទ!

ដានី ៖ ម៉ាឆ្នាំម្តងដូចថាទៅបុណ្យ ទៅសែនព្រេនអីហ្នឹង?

សាន ៖ បាទ! បើនិយាយរួមទៅ យើងទៅគ្រាន់តែឲ្យគេឃើញ មានតែបងប្អូន បើបងប្អូនគេមកនេះអស់ហើយ គ្រាន់តែទៅរំលឹកដូនតាម្តងម្កាល ព្រោះវាចោលមិនរួច ។

ដានី ៖ អញ្ចឹងខ្ញុំអរគុណពូច្រើនហើយ ។

សាន ៖ បាទ!

**«ចប់»**